ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| ៣-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១រូប | អនុប្រធាន |



www.pheakdeylaw.com

| | | |
|---|---|---|
| ៥-ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | | អនុប្រធាន |
| ៦.តំណាងក្រសួងយុត្តិធម៌ | ០៣រូប | សមាជិក |
| ៧-តំណាងក្រសួងពាណិជ្ជកម្ម | ០៣រូប | សមាជិក |
| ៨-តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី | ០៣រូប | សមាជិក |
| ៩-តំណាងក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ០៣រូប | សមាជិក។ |

**ប្រការ ២ .-**

ក្រុមការងារនេះ មានភារកិច្ចជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការសិក្សាស្រាវជ្រាវអំពីច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី និងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធផ្សេងៗ ដើម្បីផ្ដួចផ្ដើមនូវជម្រើសនានា ក្នុងការរៀបចំធ្វើវិសោធនកម្មច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី តាមការចាំបាច់។

**ប្រការ ៣ .-**

ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២ ខាងលើ ក្រុមការងារនេះមានសមត្ថកិច្ច ដូចខាងក្រោម៖

-អាចធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

-អាចបង្កើតក្រុមលេខាធិការ ដើម្បីជួយកិច្ចការរបស់ខ្លួន តាមការចាំបាច់

-ក្នុងការបំពេញការងាររបស់ខ្លួន ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងយុត្តិធម៌។

**ប្រការ ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១ រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមីនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com